**សលាកប័ត្រព័ត៌មាន៖ កម្រងអត្ថបទសិទ្ធិជាមូលដ្ឋាន៖** សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការអប់រំ

**សេរីភាពមូលដ្ឋាន៖** សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការអប់រំ

**រូបភាពរួម៖** សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការអប់រំត្រូវបានការពារដោយបទប្បញ្ញត្តិនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ សេចក្តីសម្រេចចុងក្រោយស្តីពីការចេញបញ្ជីប្រធានបទសារណាដែលហាមឃាត់និស្សិតមិនឲ្យសរសេររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ ជះឥទ្ធិពលអវិជ្ជមានជាខ្លាំងទាំងទៅលើសិទ្ធិសេរីភាពខាងការអប់រំ និងព្រមទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ហើយនេះជាការរឹតត្បិតដដែលៗចុងក្រោយទៅលើសេរីភាពខាងការបញ្ចេញមតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## សេចក្តីផ្តើម

ដោយមានការជូនដំណឹងតាមរយៈនាយកដ្ឋានស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអំពីបញ្ជីប្រធានបទសារណា ដែលត្រូវហាមឃាត់មិនឲ្យសរសេរសម្រាប់ឆ្នាំសិក្សាបច្ចុប្បន្ននេះ ("បញ្ជីហាមឃាត់") មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ពិនិត្យមើលលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ នៅក្នុងបរិបទនៃសេរីភាពខាងការអប់រំ។ សេរីភាពខាងការបញ្ចេញមតិជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ដែលផ្តល់សេរីភាពដល់មនុស្សគ្រប់រូបប្រកាន់ខ្ជាប់នូវមតិយោបល់ និងស្វះស្វែងរក ទទួល និងចែករំលែកព័ត៌មាន និងគំនិតតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។ សេរីភាពខាងការអប់រំគឺត្រូវបានរួមបញ្ចូលនៅក្នុងទស្សនៈដ៏ទូលំទូលាយនៃសេរីភាពគរុកោសល្យ ដែលក្នុងនោះក៏រួមបញ្ចូលផងដែរនូវសិទ្ធិទទួលបានការអប់រំ។ ទោះជាយ៉ាងណាក៏ដោយ សលាកប័ត្រព័ត៌មាននេះនឹងពិនិត្យមើលទៅលើសេរីភាពខាងការអប់រំ ដែលទាក់ទងនឹងសេរីភាពរបស់បុគ្គលនៅក្នុងការសិក្សាប្រធានបទណាមួយទៅតាមជម្រើសរបស់គាត់ និងអាចបញ្ចេញនូវមតិយោបល់ និងទស្សនៈខាងការអប់រំរបស់ពួកគាត់ ដែលទាក់ទងនឹងបញ្ហាចោទណាមួយ ដោយគ្មានការដាក់កំហិត ឬរឹតត្បិត។ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការអប់រំ៖ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ

ច្បាប់ប្រទេសកម្ពុជាលើកកម្ពស់ និងការពារទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិសេរីភាពខាងការអប់រំ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋខ្មែរមាន *"សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ"*។ ចំណែកឯមាត្រា៣៥ ចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិ *"ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"*។ មាត្រា៦៦ នៃរដ្ឋធម្មនុញ្ញធានានូវសេរីភាពខាងការអប់រំ។ បន្ថែមលើនេះទៀត មាត្រា១៨ នៃច្បាប់ស្តីពីការអប់រំ ("ច្បាប់អប់រំ") ចែងថា គ្រឹះស្ថានឧត្តមសិក្សាត្រូវអប់រំសិស្ស និស្សិតគ្រប់រូប ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ធនធានមនុស្សគ្រប់វិស័យ និងលើកកម្ពស់ការស្រាវជ្រាវដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ បន្ថែមលើនេះទៀត មាត្រា៣៥ នៃច្បាប់អប់រំផ្តល់ឲ្យសិស្ស និស្សិតនូវសិទ្ធិ *"បញ្ចេញទស្សនៈខាងការសិក្សារបស់ពួកគេដោយសេរី"* និងសិទ្ធិ *"សេរីភាពខាងការសិក្សា"*។

បន្ថែមលើបទប្បញ្ញត្តិដែលបានលើកឡើងខាងលើ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស ហេតុដូច្នេះ ស.ស.ស.ម និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិ។ មាត្រា១៩ នៃ ស.ស.ស.ម និង ក.អ.ស.ព.ន ចែងអំពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាសកល ដែលកម្ពុជាបានយល់ព្រម និងឲ្យសច្ចាប័នទៅលើ ក.អ.ស.ព.ន ក្នុងឆ្នាំ ១៩៩២។ បន្ថែមលើនេះទៀត មាត្រា២៦ (២) នៃស.ស.ស.ម ការពារសិទ្ធិសេរីភាពខាងការអប់រំ ឬគរុកោសល្យ។

## សេរីភាពខាងការបញ្ចេញមតិក្នុងប្រទេសកម្ពុជា៖ ការជាក់ស្តែង

ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិក្នុងប្រទេសកម្ពុជាគឺស្ថិតក្រោមគំនាប។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (រ.រ.ក) គ្រប់គ្រងយ៉ាងតឹងរឹងលើគ្រប់មធ្យោបាយនៃប្រព័ន្ធផ្សព្វផ្សាយ រួមទាំងតាមទូរទស្សន៍ និងការបោះពុម្ពផ្សាយ និងចាត់វិធានការបង្ក្រាបយ៉ាងទាន់ហាន់ទៅលើអ្នកទាំងឡាយណា ដែលខ្លួនចាត់ទុកថាបានបញ្ចេញទស្សនៈនាំអោយប៉ះពាល់ដល់រាជរដ្ឋាភិបាល និងពាក់ព័ន្ធ របស់ខ្លួន។ គេបានឃើញការបង្ក្រាបពីមុនៗមានដូចជា: ការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងនឹងអ្នកការសែតសកម្មជនសិទ្ធិមនុស្ស និងតំណាងរាស្ត្រគណបក្សជំទាស់ និងការបិទសារព័ត៌មាន និងការផ្សាយតាមមធ្យោបាយផ្សេងទៀត ហើយព្រមទាំងការគម្រាមកំហែងដកហូតវិជ្ជាជីវៈពីមេធាវីផងដែរ។ តាមរយៈការរំលោភបំពានក្នុងក្របខណ្ឌច្បាប់ និងតុលាការ

ដែលប្រកាន់បក្សពួក រាជរដ្ឋាភិបាលកម្ពុជាអាចសង្កត់សង្កិនលើសម្លេងអ្នកជំទាស់ និងដាក់កម្រិតយ៉ាងខ្លាំងទៅលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។

## សេរីភាពខាងការបញ្ចេញមតិ៖ សេរីភាពខាងការអប់រំ និងបញ្ហីហាមឃាត់

ប្រឆាំងនឹងសេរីភាពខាងការបញ្ចេញមតិដែលគួរឲ្យអស់សង្ឃឹម បញ្ហីហាមឃាត់រឹតត្បិតដល់សេរីភាពខាងការអប់រំ និងធ្វើឲ្យមានការដាក់កម្រិត ជាបន្តទៀតទៅលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ ទោះបីជានាយកផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យច្បាប់បានធ្វើការអត្ថាធិប្បាយណែនាំអំពីប្រធានបទដែលត្រូវហាមឃាត់ ដោយសារការបារម្ភក្នុងការលូចចម្លងរបស់និស្សិត ការពិនិត្យមើលយ៉ាងដិតដល់លើប្រធានបទដែលហាមឃាត់បង្ហាញថាអាចមានការជម្រុញខាងនយោបាយនៅពីក្រោយការហាមឃាត់បែបនេះ។ បញ្ហីហាមឃាត់រួមមានប្រធានបទដែលជាបញ្ហារសើបខាងផ្នែកនយោបាយដូចជា៖ ដំណោះស្រាយជម្លោះដីធ្លី និងដំណោះស្រាយជម្លោះការងារ ដែលសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងបញ្ហាទាំងពីរនេះទទួលរងនូវការរិះគន់យ៉ាងខ្លាំង។ បន្ថែមលើនេះទៀត ទាក់ទងនឹងការតិះទៀននឹងការអប់រំ ធ្លាប់មានម្តងរួចហើយកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ដែលសារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថាក្រសួងព័ត៌មានបានដកចេញសៀវភៅសិក្សាពីរក្បាលពីគ្រប់បណ្ណាគារនានាទូទាំងប្រទេស បន្ទាប់ពីមានលិខិតមួយពីរដ្ឋមន្ត្រីក្រសួង អប់រំ ដែលនិយាយថាសៀវភៅទាំងពីរនោះបង្កប់ខ្លឹមសារនយោបាយដែលពុំសមរម្យ ។

ការឈានទៅដល់ការហាមឃាត់ប្រធានបទសារណាដែលនិយាយពីបញ្ហារសើបក្នុងសង្គមធ្វើឲ្យមានការព្រួយបារម្ភថាការហាមឃាត់នេះជាយុទ្ធសាស្ត្រ ដើម្បីរឹតត្បិតការិះគន់របស់សមាជិកនៃសហគមន៍គរុកោសល្យចំពោះការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ និងការបោះឆ្នោតជាតិខាងមុខ។ បន្ថែមលើនេះទៀត ប្រធានបទជាច្រើននៅក្នុងបញ្ហីហាមឃាត់ទាក់ទងទៅនឹងទីផ្សារភាគហ៊ុន ដែលទើបតែរៀបចំបង្កើត ដែលត្រូវបានគេយល់ឃើញថាជាការបោះជំហានដើម្បីបង្ការការបោះពុម្ពផ្សាយទស្សនៈរិះគន់ ដែលអាចប៉ះពាល់ដល់ទំនុកចិត្តរបស់វិយោគិន ចំពោះការផ្តល់ជាសាធារណៈលើកដំបូងដែលត្រូវធ្វើឡើងក្នុងឆ្នាំ២០១២។ មិនថាការហាមឃាត់ប្រធានបទសារណាអាចជម្រុញផ្នែកនយោបាយ ឬការព្រួយបារម្ភអំពីការលូចចម្លងយ៉ាងណាក៏ដោយ នេះមិនអាចធ្វើឲ្យយើងមើលរម្លងនូវអង្គហេតុថាការហាមឃាត់បែបនេះនឹងរឹតត្បិតដល់សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការអប់រំ ។

## សេចក្តីសន្និដ្ឋាន

ការចេញបញ្ហីហាមឃាត់ប្រធានបទសារណាដោយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រឹតត្បិតយ៉ាងខ្លាំងទៅលើសេរីភាពខាងការអប់រំ និងបន្ថែមឲ្យស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិដែលកំពុងមានបញ្ហាស្រាប់រួចហើយនៅក្នុងប្រទេសកម្ពុជា រឹតតែធ្ងន់ធ្ងរថែមមួយកម្រិតទៀត។ ការហាមឃាត់បែបនេះផ្ទុយទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការអប់រំ ដែលមានចែងទាំងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ម.ស.ម.ក យល់ឃើញថា សាលកវិទ្យាល័យមានកាតព្វកិច្ចបង្កើតគម្រូនៃការអនុវត្តក្នុងសង្គម និងព្រមទាំងលើកទឹកចិត្តដល់សហគមន៍គរុកោសល្យឲ្យអនុវត្តភារៈកិច្ចរបស់ខ្លួនដោយគ្មានការដាក់កំហិតស្របតាមកម្មវិធីសិក្សា និងអាចឲ្យពួកគេរួមចំណែកដោយសេរីនៅក្នុងកិច្ចពិភាក្សានយោបាយ សេដ្ឋកិច្ច និងវប្បធម៌ ហើយនេះជាបុរេលក្ខខណ្ឌឈានទៅរកការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសជាតិនាពេលអនាគត។ ម.ស.ម.ក ជម្រុញឲ្យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងរាជរដ្ឋាភិបាលកម្ពុជា (ក្នុងនាមជានិយ័តករក្នុងវិស័យអប់រំ) ចាត់វិធានការចាំបាច់ដើម្បីលើកទឹកចិត្តដល់សហគមន៍ និងត្រូវធានាឲ្យមានការគោរព និងអនុវត្តរាល់បទប្បញ្ញត្តិទាក់ទងនឹងសេរីភាពខាងការអប់រំ និងសេរីភាពខាងការបញ្ចេញមតិដែលមានចែងទាំងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិដូចដែលបានរៀបរាប់លម្អិតខាងលើ៕

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៥០ ៥០ ៥១ ឬតាមរយៈអ៊ីមែល ouvirak@cchrcambodia.org ឬលោក រ៉ូប៊ឺត ហ្វីន តាមរយៈលេខ (៨៥៥) ៧៨ ៨០ ៩៩ ៦០ ឬតាមរយៈអ៊ីមែល robert.finch@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights